**បើការចាកចេញរបស់អូនធ្វើឱ្យបងបានសុខ....**

គ្មានអ្នកណាដឹង ពីករណីបាត់ខ្លួនរបស់គេ ប៉ុន្មានថ្ងៃមកនេះ ថាគេទៅទីណានោះឡើយ។ អ្វីដែលសន្សាខ្លាចបំផុតគឺ សម្តីពិនណា ដែលកំពុងកម្លោចចិត្តនាងឱ្យក្រៀមក្រញង់ដោយក្តីអស់សង្ឃឹមនិងភ័យខ្លាច។

«លទ្ធផលនៃការវះកាត់មានតែពីរប៉ុណ្ណោះ គឺ អាចចាំរឿងរ៉ាវចាស់ៗបានមកវិញឬមួយក៏ដេករហូត! ព្រោះតែការចង់ឈ្នះ ឯងយកជីវិតគេទៅប្តូរបានន័យថាឯងមានស្នេហាស្មោះ?»

សម្តីពិនណាធ្វើឱ្យកូននាគលែងចង់បានគេមកវិញ ជាមួយនឹងការប្រថុយប្រថាននោះ។

នាងចេញពីពិនណាភ្លាម ក៏ទាក់ទងទៅរកបងធម៌តែនាងមិនបានឃើញឃុនរាជហើយក៏ទាក់ទងគ្នាមិនបានទៀតព្រោះ ឃុនរាជបានទៅថៃជាមួយLorenzo តាមការហៅរបស់វឌ្ឍនៈ ទាំងវឌ្ឍនៈប្រាប់មិនឱ្យនិយាយប្រាប់អ្នកណាចំពោះរឿងនេះ។

ដោយមិនអាចរង់ចាំតទៅទៀតបាន អ្វីដែលសន្សាអាចធ្វើគឺមកកាន់ទីកន្លែងចាស់ ទីសាងស្នេហ៍ក្នុងបំណងបំបាត់ដានមិនឱ្យបុរសនោះមកដល់ឃើញ តម្រុយចាស់ គឺនាងខ្លាចគេទៅ ទទួល យកការវះកាត់ប្រកបដោយហានិភ័យនោះ។

មិនបានដឹងឡើយថា ឃុនរាជបាននាំគេមកដល់ទីនេះមុនពេលដែលនាងមកដល់៤ថ្ងៃទៅហើយ។

នៅក្រោមពន្លឺចុងក្រោយនៃទិនករហៀបលិច ស្រីស្អាតកាន់ពែងតែអង្គុយទទួលយកសន្សើមជើងភ្នំតែម្នាក់ឯង។

មនុស្សយើង បើនៅសុខៗ ទឹកភ្នែកលែងហូរ ចិត្តលែងផ្សារពើត មាត់លែងសោកសៅ តែញញឹមក៏លែងចេញ តើជីវិតបន្តទៅមុខ ជាឆាកអ្វីទៅ?

«បើនៅភ្នំពេញមិនសប្បាយចិត្តដដែល មកនៅនេះវិញមកហ្អីក្មួយ?!»

នាងខំញញឹមទទួលវត្តមានម្តាយចិញ្ចឹមដែលមកដល់ចប្រប់ពីក្រោយខ្នង កំពុងបបោសដីផងបោចស្មៅបរិវេណផ្ទះផង។

ស្ត្រីនេះ និងស្វាមី បានរើសនាងមកចិញ្ចឹមតាំងពីតូចក្រូចឆ្មារ ពេលនេះទៀតសោតគាត់នៅតែយកចិត្តទុកដាក់ ព្រោះថាចាប់តាំងពីរកឃើញគ្រួសារពិតរបស់ខ្លួនឯងរួចកាលណា នាងក៏បាត់បង់ស្នាមញញឹម ចរិតរួសរាយរាក់ទាក់ក៏ដូចជាភាពស្វាហាប់ដែលម្ចាស់ផ្ទះអនាគតធ្លាប់មាន។

ចាប់តាំងពី៦ឆ្នាំមុន វត្តមានចុងក្រោយរបស់Lorenzoនៅឯកម្មវិធីផ្តល់អំណោយ ក្មេងៗមិនមករៀនក្នុងកូនផ្ទះនេះទៀតទេ។ វាក្លាយជាទីកន្លែងបង្កប់ចោលនូវអាថ៌កំបាំងបែកគ្នានៃមនុស្សពីរនាក់ដែលមិនធ្លាប់មានអ្នកភូមិណាម្នាក់អាចបកស្រាយចេញ។

«ចុះអាគារថ្នាក់រៀនដែលក្មេងៗរៀន មានអ្នកសំអាតដែរមីង?»

«កុំព្រួយ!ត្បិតតែខែវ៉ាកង អ្នកភូមិមិនជាប់បុណ្យទានច្រើន តែពូឯងមិនដែលចោលសាលាទេ គាត់ចែកវេនជាមួយមេភូមិរកអ្នកថែទាំរហូត!»

ស្ត្រីដាក់អំបោសចុះ ដើរមួយៗ មករកកូននាគសំណព្វចិត្តពេលឃើញនាងស្ងៀមជាមួយពែងតែតូចលែងចេញវាចាអ្វី។

មកអង្គុយពីក្រោយកៀកគ្នាហើយនាងក៏មិនបានសាសងអ្វីបន្ថែមធ្វើឱ្យម្តាយចិញ្ចឹមរូបនេះ កាន់តែដង្ហើមធំ។

គាត់មិនសូវចេះនិយាយច្រើន មិនចេះលើកទឹកចិត្តអ្វីដូចអ្នកទីក្រុង ប៉ុន្តែគាត់មានបេះដូងទៀងត្រង់និងយល់ចិត្តមនុស្សជាងអ្នកទីក្រុងទាំងឡាយដែលកូននាគបានស្គាល់។

«ខ្ញុំមិនអីទេមីង! ឈប់គិតរឿងខ្ញុំទៅ!»

គាត់កាន់តែដកដង្ហើមវែង ធ្វើឱ្យនាងបំបែរខ្លួនឯងមកវិញហើយញញឹមកំដរបរិយាកាស។ត្បិតតែនាងមិននិយាយ ត្បិតតែនាងខំញញឹមបន្លំ តែអ្នកដែលបានបីបាច់នាងតាំងពីតូចក្រូចឆ្មារមកទល់ពេលឥឡូវនេះ គឺគាត់មិនដែលស្រណុកចិត្តម្តងណាឡើយចាប់ពីពេលដែលសន្យាលែងដូចមុន។

«សេដ្ឋីក្មេងហ្នឹងគេជិតចូលរោងជាមួយប្អូនស្រីក្មួយហើយ?ៗ»

នាងទម្លាក់ទឹកមុខជាមួយសំណួរដំបូងដែលម្តាយធម៌ម្នាក់នេះដាច់ចិត្តហារមាត់មកសួរនាំ។ មានតែលើកតែក្រេបដើម្បីទប់ទល់ពេលវេលាខ្លីមួយឱ្យខ្លួនឯងអាចសម្រួលទឹកមុខល្អមើលជាងនេះ។

នាងក្រេបហើយ ទើបឆ្លើយខ្សឹបៗល្មមឮតែពីរនាក់៖

«ប្រហែលគ្រប់យ៉ាងជាព្រហ្មលិខិត !»

នាងវាចាជាលើកដំបូងនូវប្រយោគដែលបង្ហាញថា នាងលែងមានៈរង់ចាំគេទៀតហើយ។

៦ឆ្នាំមកនេះ មិនដែលមានអ្នកណាម្នាក់ក្នុងភូមិធ្លាប់គិតថា ស្រីតូចខ្វាត់ព្រាត់ម្នាក់ដែលពួកគេស្គាល់ថាមានចរិតរបិលរប៉ូច តែមហិច្ឆតាសប្បុរសធំ ទូលាយនិងសន្តានចិត្តចំពោះខ្សែជីវិតសែនរឹងមាំ មានស្នេហាស្មោះនិងសុទិដ្ឋិនិយមម្នាក់នេះ ព្រមជឿលើវាសនា និងចំណារព្រហ្មលិខិតអ្វីនោះឡើយ។

ម្ដាយធម៌ងក់ក្បាល ផ្ទួនពាក្យនាង។

«បើអ៊ីចឹងក៏អ៊ីចឹងទៅ!មកនៅទីនេះលំហែសិនក៏ល្អ ចាំមីងរើមកគេងជាមួយ ចាំសប្បាយចិត្តចាំត្រឡប់ទៅវិញ! បើអត់ទេ ក៏មិនបាច់ទៅណាទៀតដែរ!»

នាងលោដៃទៅឱបក្រសោបគាត់ ទាំងមិននិយាយស្ដីអ្វី។

នាងឈប់បន្ទោសហើយថាហេតុអ្វីសន្យាកាលពីល្ងាចនោះចាំបាច់ជួបគ្នាជាមួយLorenzoដែលមានរបួសធ្លាក់មកពីជម្រាលភ្នំ ហើយហេតុអ្វីជួបគេហើយ នាងបែកគេទៅវិញបានដោយសារឧប្បត្តិហេតុមួយនោះ?

«មនុស្សពីរនាក់ ដែលមានតែនិស្ស័យតែគ្មាន វាសនា បើជម្នះក៏គង់តែបានត្រឹមខ្លោចផ្សារៀងៗ បើមានៈចង់ជួបគ្នាទាំងដូច្នេះទៀត! ខ្ញុំឲ្យគេសប្បាយចិត្តចំពោះបច្ចុប្បន្នកាលរបស់គេចុះមីង!»

ស្ត្រីលើកដៃជូតទឹកភ្នែកធ្វើឱ្យស្ត្រីតូចកាន់តែឱបគាត់ណែនលើសមុន។

នាងនៅស្ងប់ស្ងៀមកំដរគាត់យំទាំងបេះដូងខ្លួនឯងហាក់ស្ងប់ហើយអស់ទៅហើយ នូវអ្វីដែលហៅថារសជាតិនៃទឹកដមស្នេហ៍ ដែលខំថៃក្ដីសង្ឃឹមឱ្យខ្លួនឯងរហូត មករង់ចាំគេ។

«មិនដឹងថាតើគួរឈឺចាប់ឬ លែងចេះឈឺទេមីង! ប្រសិនទាមទារឱ្យគេបានអតីតកាលមកវិញហើយគេពិការ ឬកើតទុក្ខដូចខ្ញុំពេលនេះ ខ្ញុំឈប់ទារយកការពិតពីក្នុងបេះដូងគេទៀតហើយ!ឱ្យគេភ្លេចវាចុះណ៎ាមីង!»

បាននិយាយពាក្យពិតចេញមកជាមួយមនុស្សគួរជាទីទុកចិត្តណាម្នាក់គឺជាសំណាងមួយសម្រាប់មនុស្សខូចចិត្តដូចនាង។

ការប្រឈមនឹងហានិភ័យខ្ពស់របស់គេ នាងមិនយកល្អជាង នូវលទ្ធផលដែលនាំឱ្យទាំងអស់គ្នាធ្លាក់ទៅក្នុងនរក។

អូនមិនអាចមើលឃើញបងពិការ ដូរមកជាមួយការចងចាំ រឿងយើងទេLorenzo! មិនបានអាត្មានិយមដូចគ្រប់គ្នាគិតឡើយ! បើមិនបាច់រស់ជាមួយបងហើយឃើញបងបានសុខអូនទទួលយកបាន។

នាងនឹកឃើញដល់អ្វីម្យ៉ាង ត្រូវហើយ!

ស្រីស្អាតបែរសន្សឹមមករកបាច់ផ្កាដែលនៅក្រៀមក្រញង់ជាមួយសំបុត្រពណ៌ជម្ពូកណ្ដាលបន្ទប់....

«មីង!បងធម៌ខ្ញុំ ឈុនរាជដែលមកលេងនេះអត់ប៉ុន្មានថ្ងៃនេះ?!»

មីងនៅស្ងៀមរកនឹកមុនពេលវាចាតបះ

«ចាំសួរយាយហុកនិងតាហឿនឱ្យ!មីងទើបមកពីបុណ្យនៅកំពង់ឆ្នាំង!ទៅ៥ថ្ងៃហើយ មិនបានមកក្បែរៗនេះទេ! តែតាមមើលអត់ទាន់ទេដឹង? ព្រោះឈុនរាជខានឃើញយូរហើយ!ឱ្យតែមកលេងដឹកនំប៉័ងមកផ្ញើផ្អើលអ្នកស្រុកមិនដែលលោះទេ!»

នាងធូរចិត្ត។

ស្រីតូចក្រោកសន្សឹមៗហើយដើរចូលមកក្នុងផ្ទះ ចំណែកស្ត្រីជាម្ដាយធម៌នៅបន្តការងារសំអាតរបស់គាត់។

មាត់គាត់ស្រែកមកពីក្រោយខ្នងនាង៖

«ឪឡឹកទុំច្រើនណាស់! ចាំល្ងាចទៅបេះជាមួយមីង!»

«ចាំ!»

ពីមុនការងារបេះផលាជារឿងដែលខ្លួននាងសប្បាយចិត្តបំផុត ក៏ជាសកម្មភាពដែលម្ដាយធម៌តែងកំដរនាងធ្វើ ប្រសិនពេលសង្កេតឃើញនាងមិនសប្បាយចិត្តម្ដងៗ តែពេលនេះ គ្រប់យ៉ាងគ្រាន់ទេបង្គ្រប់កិច្ច មិនចង់ឱ្យពួកគាត់គិតច្រើនហើយពិបាកចិត្តចំពោះស្ថានភាពនាង។

ចិត្តនាងនៅតែផ្ដោតលើបាច់ផ្កាក្រៀម ហើយលូកដៃលើកវាចេញមកជាមួយនឹងកូនសំបុត្រនោះផងដែរ។

«ខ្ញុំគិតខុសហើយ ដែលរក្សាទុកឯងរហូតដល់ពេលនេះ! តាមថា ឯងលែងស្រស់យូរហើយ!ទុកឯងក្រៀមអញ្ចឹង ហើយឱ្យឯងនៅឯការអញ្ចឹងទៀតជាកំហុសរបស់យើង!»

បងឱ្យវត្ថុអនុស្សាវរីយ៍ចុងក្រោយមុនឡើងឡានហើយបញ្ឆេះចេញក្រោមការតាមសម្លឹងរបស់ម្ដាយ។

រឿងចាស់ ក៏ជារឿងចុងក្រោយ លេចឡើងមកវិញក្នុងការចងចាំច្បាស់ដូចថ្ងៃ.....

គឺព្រឹកមួយដែលនាងចេញពីពិធីបរិច្ចាគ ដែលគេចាប់កដៃនាងឱ្យឡើងឡានទៅជាមួយគេ.....

នាងចាំជានិច្ចសម្ដីគេដែលនិយាយជានិច្ចថា «ទោះមានរឿងអីកើតឡើងក៏ដោយកុំចោលបងឱ្យសោះ !»

Lorenzo ព្រោះពាក្យរបស់លោក ខ្ញុំបានទៅរកលោកម្ដងហើយម្ដងទៀតទាំងដែលលោកមិនត្រូវការខ្ញុំ ទាំងដែលគ្រប់គ្នាទុកខ្ញុំថាជាមនុស្សស្រីមិនចេះអៀនខ្មាស។

ពាក្យស្នេហានិងចិត្តសន្យាដែលដឹងត្រឹមពីរនាក់ ខ្ញុំមិនខ្វល់ឡើយថាអ្នកណាគិតពីយើងក្នុងរបៀបយ៉ាងណា ដឹងត្រឹមថា ចិត្តនេះ មិនដែលក្បត់លោក ក៏មិនដែលបំភ្លេចស្នេហាមួយនេះ ទោះជាមានអ្វីកើតឡើងក៏ដោយ។

«ខ្ញុំសន្យា!»

នេះគឺសម្ដីនាងដែលឆ្លើយតបនឹងកែវភ្នែកសុំអង្វររបស់គេ ក្នុងឡានណា ព្រឹកនោះ គឺតបនឹងសម្ដីគេដែលសួរនាងត្រង់ៗ«ស្រលាញ់បងបែបនេះរហូតឬអត់?!»«ទោះមានរឿងអីកើតឡើងក៏ដោយកុំចោលបងឱ្យសោះ!»

គេនិយាយមកខ្សឹបៗ នាងនៅគាំងជ្រកក្នុងដើមទ្រូងកក់ក្ដៅសន្ធំដោយភ្លើងស្នេហ៍របស់នាយ។ តែចិត្តនាងពិតប្រាកដពេលនេះវិញ លែងរងាឬកក់ក្ដៅទៀតហើយ។ ក្បែរទ្រូងលែងមានគេ គេជិតចូលរោងការ ហើយហៅមនុស្សស្រីផ្សេងថា ប្រពន្ធ ចំណែកយើងនេះ ជាស្អីដែរទៅ?

បានត្រឹមឱបរបស់នេះ?

នាងឱនសម្លឹងបាច់ផ្កាដែលនៅជាប់ទ្រូងនិងកូនសំបុត្រក្បែរប្រអប់លេខរថយន្ត។

«តោះ ទៅកន្លែងស្អាតមួយ!»

សម្ដីនាងកាលពីពេលនោះ គឺជាគ្រាដំបូងដែលនៅក្នុងទ្រូងគេ ដោយមានតែពីរនាក់តទល់ហើយគេមានចេតនាប្រាប់នាងពីការពិតទាំងអស់ថាគេជា Lorenzoពិតប្រាកដមិនមែនជាកម្មករនេសាទកម្សត់មិនចេះសូម្បីតែភាសាអង់គ្លេសដូចដែលនាងធ្លាប់ស្មាននោះឡើយ។

**បើមានរឿងអ្វីកើតឡើងបងទទួលយកវាជំនួសអូន**

«ទៅណាអា្ហកូនក្មេង!កុំរលាមពេកនៅហ្នឹងហើយ នៅឱ្យសៀមម្តងមើល៍លែងរត់ចុះឡើង!»

«ឱទ្បឹកទុំច្រើនណាស់ទាន់មានឡានស្រាប់យើងទៅបេះវាដឹកទៅ ទាន់មានឡានមកដែរ ! យកមក ចែកអ្នកដែលគេខំមកចូលបរិច្ចាគលុយ!របស់ធម្មជាតិណា!»

នាងនិយាយហើយអូសដៃគេឱ្យលែងចេញពីចង្កេះខ្លួនតែបុរសនៅតែមិនព្រមរឹតតែផ្ទឹបបបូរមាត់មក លើសរសៃសក់។

សំឡេងគេង៉ុលៗលាន់មកគ្រប់ពីលើបេះដូងក្មេងខ្ចីរបស់នាង៖

«ម្ចាស់អំណោយនៅទីនេះ ! វាមិនចង់បានឱទ្បឹកយកធ្វើអីទេ ! វាចង់បានម្ចាស់ឱទ្បឹក!»

ម្រាមដៃគេច្រវាត់ជំពាក់ជាមួយម្រាមទាំងដប់របស់នាង រីឯមាត់រាងកាយនាយរឹតតែស្អិតជាប់គ្នា ហាក់បញ្ជាក់ឱ្យនាងឈប់គិតពីរឿងបានចេញពីរង្វង់ទ្រូងនាយទៀតទៅ។

បបូរមាត់បុរសនេះកាន់តែរត់រសឹបចុះមកក្បែរគល់សក់ ហើយគេប្រលែងលេងវានៅទីនោះធ្វើឱ្យ មនុស្សស្រីក្មេងសេចក្តីដែលមិនធ្លាប់ស្គាល់អ្វីថាជាសេចក្តីស្នេហា បាត់បង់កម្លាំងកាយនិងប្រាជ្ញាក្នុង ការតតាំងជាមួយល្បែងបង្កាត់ភ្លើងស្នេហ៍នៃព្រាននារីថ្មីកដៃម្នាក់នេះស្រេចទៅហើយ។

ហើយសាជាថ្មី ម្តងទៀតដូចកាលពីមុនដំបូងដែរ គឺ គេទាញប្រាណនាងឱ្យមកស្គាល់ប្រាណគេទាំង ស្រុងមិនមានកន្លុកកន្លៀតណាដែលមិនប៉ះគ្នាទាំងអស់។

ទាំងមិនបានដោះសម្លៀកបំពាក់ ក៏នាងមានអារម្មណ៍ថាដូចជារាងកាយទាំងស្រុងក្លាយជាកម្មសិទ្ធិ នៃបុរសនេះ រួចទៅហើយ។

ទោះប្រឹងបិទភ្នែកធ្វើជាមើលមិនឃើញអ្វីក៏កាន់តែមើលមិនឃើញកាន់តែមានអារម្មណ៍ដឹង ពីសេចក្តី ទាមទារខាងភេទរបស់គេ ដែលកំពុងបញ្ចេញមកលើចំណាប់ខ្ទាំងក្នុងដៃ។

ដៃបុរសនេះ បញ្ជាទាមម្រាមនាងឱ្យព័ទ្ធទៅឱបគេវិញម្តង ទាំងដែលនាងគ្មានកម្លាំងតបត រើបម្រះ ព្រោះ តែស្នាមថើបអម្បាញ់មិញបានបោះបង់ចោលសក់របស់នាង ទៅមួយអន្លើហើយប្តូរមកទន្ទ្រាន ពាសពេញក្នុងបបូរមាត់ស្រីក្មេង។

អណ្តាតរបស់គេវែងនិងទន់ល្មើយ ក្តៅធំ រស់ររើក រំលឹកមកជាមួយនូវពាក្យពេចន៍ នារាត្រីដំបូងមួយ «ខ្ញុំស្មានបងឯងអ្នកនៅភ្នំពេញដឹងរឿងច្រើនជាងខ្ញុំ ដឹងអី បងឯងយ៉ាប់ជាខ្ញុំមួយយោជន៍!»

«ស្អីទៅមួយយោជន៍?»

«អ្ហូយ! ខ្មែរក៏មិនចេះ? រៀនបានថ្នាក់ទីប៉ុន្មាន?»

«យប់មិញ ខ្លួនឯងសរសើរថាបងមានក្លិនទឹកអប់ជាអ្នកភ្នំពេញ?»

«ទឹកអប់អាចលួចគេលាប! មានអីសម្គាល់ថាអស្ចារ្យទេ! ឥឡូវប្រាប់មក បងឯងមកពីណា? មានប្រភពមកពីកន្លែងណា? ម៉េចមកបង្ហាញមុខម៉ុំៗនេះ? អ្ហ៎ូខ្ញុំនេះភ្លេចគិត ពាក្យចាស់គេថា មនុស្សខ្វាត់ភ្លាត់ មិនដឹងប្រវត្តិត្រូវប្រយ័ត្ន ដូចជាចង់ជ្រុលក្បាលក្រពើហើយខ្ញុំនៀក!»

ត្រូវហើយ នាងកំពុងជ្រុលក្បាលក្រពើ ទៅមុខមិនបាន ថយក្រោយកាន់តែអត់រួច។ កុំថាឡើយរើ សូម្បីហារមាត់អង្វរបុរសនេះឱ្យដឹងប្រាណមកវិញក៏ដូចជាគ្មានសង្ឃឹមធ្វើ។

គេមិនមែនបងកម្មករនេសាទកម្សត់ តែគេកំពុងបញ្ចេញពិសនៃស្ដេចពស់នាគរាជ ដែលនាងមិនធ្លាប់ដឹង ហើយរឹតរួតរុំជុំវិញស្រីតូច មិនឱ្យសូម្បីតែនឹងចង់សម្រាកចេញពីការប្លូរ ដង្ហើមជាមួយគេ។

ដោយអំណាចនៃ ភ្លើងតណ្ហាគ្របដណ្ដប់ ងងឹតស្លុបទាំងពីរកាយ ដៃគេបញ្ជូនម្រាមស្រីស្អាតទៅប៉ះពាល់ទីសម្ងាត់ដ៏សំខាន់ នៃជីវិតមនុស្សប្រុស ធ្វើឱ្យនាងប្រកែកតវ៉ា ដូចសត្វម្រឹគមិនហ៊ានទៅមុខសូម្បីត្រឹមឃើញស្នាមជើងដំរី ចំណែកការប្រកែកញ៉ាញនៃមនុស្សស្រីធ្វើឱ្យចិត្តបុរសនេះរឹងរឹតតែចង់បាននាងមកក្រោមការគ្រប់គ្រង។

ពាក្យសន្ទនាដែលរក្សាទុកជ្រៅសែនជ្រៅក្នុងបេះដូងនៃបុរសនេះ បានក្លាយជាងើកភ្លើងស្នេហ៍ដែលកំពុងរាលឆេះមករាប់រយអង្សាចង់អ្នកណាមកពន្លត់ពេលនេះក៏មិនបានដូចគ្នា....ដៃគេបាននាងតែចិត្តគេនឹកនាង ដូចជាកំពុងនៅឆ្ងាយពីគ្នា ខ្លាចតែព្រាត់គ្នា ហើយគិតពីគ្នាមិនចេះធ្អឹតធ្អន់....

«ថ្ងៃក្រោយ! ឈប់ទៅនៅឆ្ងាយរបៀបនេះទៅ! ផ្ទះអនាគតនោះ វាឆ្ងាយ វាជ្រៅពេកហើយ! ខ្លួនធំហើយត្រូវនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្ដាយ!»

»បងឯងនៅតែលើសមុទ្រធ្វើកម្មករគេ អត់ចេះអង់គ្លេសទេមែនអត់? ស្អែកខ្ញុំបង្រៀនក្មេងៗ បងឯងចង់រៀនអត់?»

បុរសលែងដៃពីនាងយឺតៗ ហើយក៏ថយក្រោយពីសមរភូមិក្នុងមាត់នាងសន្សឹមៗ។

គេចង់ថយមក ព្រោះចង់ប្រើភ្នែកមើលនាង មើលមនុស្សស្រីម្នាក់ដែលពេលនេះ ឥឡូវនេះកំពុងមានតម្លៃស្មើជីវិតរបស់នាយ។

នាងឱនមុខ មិនហ៊ានសូម្បីតែបើកភ្នែកសម្លឹងជុំវិញខ្លួនកុំថាឡើយសម្លឹងមនុស្សប្រុសម្នាក់ដែលកំពុងគ្រប់គ្រងជីវិតខ្លួន។

ដៃនាងទាំងទ្វេនៅតែស្ថិតក្រោមប្រអប់ដៃ Lorenzo ឯគេក៏ឈ្ងោកមកឱបនាងណែនជាងមុនទៅទៀត ព្រោះទំហំនៃចិត្តអាណិតស្រលាញ់។

«សុំទោស ដែលនិយាយកុហករហូតមក! សុំទោសដែលមិនបានប្រាប់

ថាបងជាអ្នកណា!»

«អ៊ីចឹងបងឯងជាអ្នកណាទៅ? !»

ត្រូវលត់ខ្លាំងដែរហើយនៅតែចម្រែតមកវិញមិនចោលទម្លាប់។ សម្តីប្រដេញសួរមិនបានចាកចេញពីចរិតស្រីម្នាក់នេះពិតមែនហើយ។ នាយសើចខឹកៗរង្គើបេះដូង  ពេលដែលម្រាមដៃលែងកាយនាងហើយបំបែរមុខស្រីតូចឡើងមកដើម្បីឱ្យបានឃើញគ្នា។

គេនិយាយបន្តមួយៗខ្សាវៗតបតនឹងកែវភ្នែកម៉ក់ៗរបស់នាង៖

«វាអត់សំខាន់!ទោះបងជាអ្នកណាជាកម្មករនេសាទឬមួយ Lorenzoបងនៅតែគ្មានថ្ងៃចាកចេញពីកូននាគតូចរបស់បងទេ !»

ទោះនាងសួរចម្រែតតែភ្នែកនាងស្រទន់ណាស់ហើយស្លូតបំផុតក្នុងចំណោមពេលវេលាទាំងអស់ដែលគេធ្លាប់នែបនិត្យក្បែរ។ ប្រាកដណាស់ ជាតិនេះនាងលែងអាចរស់នៅជាមួយប្រុសណាផ្សេងដោយមិននឹកគេទៀតហើយ។

នេះជាអារម្មណ៍សម្ងាត់នៃមនុស្សស្រលាញ់គ្នា ។

នាងស្រាប់តែរើខ្លួនប្រុងថយពីរាងកាយគេដែលកំពុងស្និទ្ធជាប់សាច់ សូម្បីដកដង្ហើមក៏រង្គើដល់គ្នាបាន។តែខាងប្រុសប្រទាញមកដដែលវិញដោយអង្អែលផែនថ្ពាល់ក្រពុំរលោងនាងយឺតៗកំដរម្រាមដៃស្តាំ។

ដៃឆ្វេងនរះនេះ លូកទម្រេតកៅអីស្រី បណ្តោយឱ្យទ្រូងនាយកាន់តែអាចទ្រោបមកលើនាងបាន មុនពេលដៃគេរាវទៅរកខ្សែរូតនៅពីក្រោយខ្នងតូចនារី។

បានត្រឹមប៉ះទ្រូងនាយដោយម្រាមទាំង១០តែក៏គ្មានកម្លាំងច្រានរឹតតែទីទើរមិនចង់ច្រានបុរសនេះចេញសោះ។

តែប្រសិនបើកូននាគតូចបណ្ដោយឱ្យ Lorenzoដោះអាវនាងចេញបានពិតមែនគ្រប់យ៉ាងនឹងទៅជាយ៉ាងណា?

នាងមិនដែលបានត្រៀមចិត្តឬសូម្បីតែនឹងគិតថា អ្នកជំងឺរបស់ខ្លួន នឹងក្លាយជាព្រានដៃឆៅកម្រិតនេះ។

«ឈ្មោះបងឯងក៏ខ្ញុំមិនស្គាល់ផង!»

នាងនិយាយទាំងអន់ចិត្តហើយដៃច្រានទាយចេញជានិច្ច ទោះបីប្រាណបុរសនេះធ្ងន់ប៉ុណ្ណា។

នាងធ្លាប់គ្រាប់គេឡើងមកពីជម្រាលភ្នំ ថែមទាំងធ្លាប់ដឹកគេបាន តែលើកនេះ នាងបែរជាភាគីខ្សោយក្នុងដៃគេ តែទឹកមុខនាងមិនបានខ្សោយទេ ព្រោះគេកំពុងធ្វើឱ្យនាងមានអារម្មណ៍ដ៏វិសេសជាមនុស្សដែលគេចង់ស្វែងយល់ ចង់គ្រប់គ្រងនិងចង់បើកកកាយទាំងអស់នូវបណ្ដាអាថ៌កំបាំងលើរាងកាយនាង ដែលមិនធ្លាប់មានបុរសណាហ៊ាន។

«Lorenzo ឈ្មោះខ្មែរជំនិត វីរៈ ស្រលាញ់មួយណាហៅមួយហ្នឹងទៅ!»

«អត់ចង់ហៅទាំងអស់!»

«ចង់អីវិញ?!»

គេសួរទាំងខាំមាត់ក្នាញ់ហើយ ជាមួយម្រាមដៃ លូកត្របាញ់ទៅក្នុងសំពត់នាង ។ ស្រីតូចស្រែកយ៉ៃក្រឡាស់ខ្លួនគេចពីភាពអាសអាភាសនៃកំសួលតណ្ហាប្រុសស្នេហ៍។

«ខ្ញុំហៅបងLoren ឈប់ធ្វើអ៊ីចឹងទៅ!»

ប្រុសសង្ហាញញឹមខ្ចឹប បណ្ដោយឱ្យនាងទាញដៃគេហើយច្រានចេញ ពីរាងកាយ។ ម្ដងជាពីរដងគេលូកមកទៀតតែលូកមកក៏ដើម្បីតែឱ្យនាងច្រានចេញតែប៉ុណ្ណោះ។

«បងឯងឈប់ធ្វើបាបគេហ៍!»

«មនុស្សស្រលាញ់គ្នា!»

គេតបតិចៗនឹងកែវភ្នែកនាងឯបាតដៃក៏នៅតែពពាក់ពពូនគល់ពោះនិងភ្លៅរបស់នាងមិនឈប់ឈរ។

មាត់បុរសនេះនិយាយភាសាខ្មែរច្បាស់ជាងដែលប្រុសខ្មែរផ្សេងៗចេះនិយាយទៅកាន់ស្រីស្នេហ៍របស់គេទៅទៀត ។ Lorenzo បញ្ឈឺនាងច្រមក់បន្ថែមដោយដៀមដាម៖

«ចង់បានអណ្ដូងគេរាប់រយ គេឱ្យបានតាមសំណូមពរ ចំណែកអណ្ដូងខ្លួនតែមួយ ក៏ កំណាញ់ម៉េះអ្ហះ?!»

 ជាមួយនឹងសំពត់នៃភាពរាលដាលពាសពេញរាងកាយដោយភ្លើងស្នេហ៍ដែលនាយបង្កាត់ ស្រីស្អាតត្រូវភាំងលែងនិយាយរួចអ្វីតបទៅនឹងពាក្យសិកសៀតរបស់គូស្នេហ៍។នាងនៅគេងសម្លឹងមុខនាយមុខយ៉ាងស្ងៀមស្ងាត់ជាមួយអារម្មណ៍កក់ក្ដៅនិងទុកចិត្តក្នុងពេលតែមួយថា នេះជាមនុស្សប្រុសដែលនាងស្រលាញ់បំផុតមិនអាចភ្លេចបានជារៀងរហូតហើយ។ ដោយមានអារម្មណ៍ដូចជាមានអ្វីម្យ៉ាងកំពុងកក្រើករំពើកក្នុងទ្រូង ជាជម្លោះរវាងចំណង់ភ្លើងស្នេហ៍និងការតវ៉ានៃក្បួនច្បាប់ជាកូនស្រីកសិករនាងមិននិយាយអ្វីឬតវ៉ាក្រៅតែពីបញ្ចេញភាពអង្វរករតាមពន្លឺភ្នែកដែលឆក់ជាប់គ្នារវាងរាងកាយពីរ។

«អ្នកណាដាក់ឈ្មោះគេថាវែង មិនចង់ដឹងថាវែងពិតមែនដែរអត់ទេអ្ហះ ក្មេងខូច?!»

នាងបិទភ្នែកស្រឹបព្រោះអៀនខ្មាសហើយនាងមិនដឹងទេថាថ្ពាល់ទាំងសងដែលកំពុងប្រែក្រហមដូចទន្លាប់ទុំ និងសន្ទឹកតឹងថប់នៃដង្ហើម ក្រោមសង្វាក់ទ្រូងពើងជាបទភ្លេងស្នេហ៍នាពេលនេះចង់សុភាពបុរសមកពីឋានណាក៏ពិបាកនឹងរក្សាទុកព្រហ្មចារីឱ្យនាងតទៅទៀតដែរ កុំថាឡើយតារាសប្បុរសដ៏ឆ្នើងកន្ទ្រើងជើងឆើត Lorenzo។

«បិទភ្នែកធ្វើអី ? សារភាពមកបានអត់ថាព្រម!»

នាងគ្រវីក្បាលតតាត់ តែក៏មិនបើកភ្នែក។

បុរសនិយាយបន្ត៖

«មិនអាណិតបន្តិចណាទេហ្អី?»

នាងនៅតែគ្រវីក្បាល មិនឆ្លើយ។ ដៃឆ្វេងបុរសនេះលូកអង្អែលកំភួនជើងស្ដាំនាងដោយលើកវាមកព័ទ្ធចង្កេះនាយហើយធ្វើសកម្មភាពដណ្ដើមយកតួនាទីជាម្ចាស់ឯកសិទ្ធិលើដើមទ្រូងនាងជាមួយនាសារបស់នាយ។

«បងឯងមកកម្ពុជាធ្វើអី?ហេតុអីមកដល់នេះចាំបាច់កុហកលាក់ប្រវត្តិ!»

សំណួរនាងធ្វើឱ្យនាយរំឭកឡើងមកវិញនូវរឿងរ៉ាវជាច្រើន។

បណ្ដាសាដែលLorenzo អាចធ្វើឱ្យមានបញ្ហាដល់បណ្ដាមនុស្សដែលគេស្រលាញ់គឺជាដើមចមនៃការផុងខ្លួននៃអភិជនកំលោះម្នាក់នេះទៅក្នុងសំណុំរឿង មនុស្សស្រីឆ្នាំនាគ៣៥នាក់ ។

មនុស្សជាច្រើនបានរងគ្រោះដោយសារគេទៅហើយ ចំណែកកូននាគកម្សត់តូចច្រឡឹងនេះ មិនអាចក្លាយជាអ្នករងគ្រោះបន្ទាប់ទៀយ។

គេងើបមុខឡើងមកវិញយឺតៗ ជាមួយនឹងការរលាយបាត់សន្សឹមៗនៃចំណង់ផ្លូវភេទ.....

គេនឹកឃើញដល់រឿងចាស់ៗ ដែលកន្លងទៅយូរណាស់មកហើយ.....គឺហេតុផលដែលនាំឱ្យគេភ្លាត់កាយ ធ្លាក់ខ្លួនឆ្ងាយមកជួបនាង.....

«បងចាញ់កលគេ!»

គេនិយាយតិចៗហើយក្រោកឡើងមកវិញព្រមទាំងទាញកៅអីយកស្រីក្មេងឱ្យក្រោកមកជាមួយគ្នា។

«បងចង់ទៅរកកន្លែងណាមួយដែលមានតែយើងពីរនាក់ហើយប្រាប់រឿងរ៉ាវទាំងអស់ដល់អូន!»

គេមានភាពស្រពាប់ស្រពោនលើផ្ទៃមុខ។

វាជាពេលដែលនាងដឹងថាបុរសនេះតាមពិតជាទេវបុត្ត Lorenzoកំពូលតារាសប្បុរសដ៏ល្បីរន្ទឺនៅភ្នំពេញចំណែករឿងដែលគេត្រូវធ្លាក់ខ្លួនរងគ្រោះរិះសូន្យជីវិត រហូតបានគុណនាងជួយឱ្យរស់រានមកវិញថែមទាំងត្រូវប្រុងប្រយ័ត្នសូម្បីតែនឹងប្រាប់អំពីបុគ្គលភាពពិតដល់នាងក៏មិនទាន់ហ៊ាន។ រហូតដល់ពេលនេះដែលគេយល់ថា វាសមល្មមក្នុងការបណ្ដោយឱ្យមនុស្សស្រីដែលសំខាន់ជាងគេក្នុងជីវិតស្គាល់សាវតារហើយបានជាគេនាំនាងមកកាន់តំបន់ធម្មជាតិស្ងប់ស្ងាត់មួយ ហើយឈប់ឡានដឹកដៃនាងចុះ។

ទំនាក់ទំនងជាវសៀវភៅ ០១៥២១៣១១១